ជោគជ័យ ហ្វាយនែន

ជម្រើសប្រសើរបំផុតដើម្បីជោគជ័យ

# របាយការណ៍ ប្រចាំឆ្នាំ ២០២០

20



# មាតិកា


**សាររបស់លោកប្រធានក្រុមប្រឹក្សាភិបាល** ........ ២
**សាររបស់លោកអគ្គនាយក** ........ ៤

**អំពីជោគជ័យ**
- ប្រវត្តិសង្ខេបរបស់ជោគជ័យ ........ ៧
- ភាគទុនិក ........ ៨
- ចក្ខុវិស័យ បេសកកម្ម វប្បធម៌ និង ទស្សនៈវិស័យ ........ ១០
- រចនាសម្ព័ន្ធគ្រឹះស្ថាន ........ ១២
- ក្រុមប្រឹក្សាភិបាល ........ ១៤
- គណៈគ្រប់គ្រង ........ ១៥
- ប្រភពទុនវិនិយោគ និងដៃគូសហការ ........ ២២

**សមិទ្ធផលអាជីវកម្មឆ្នាំ២០២០**
- តារាងសង្ខេបលទ្ធផល ........ ២៤
- ផលិតផលកម្ចី ........ ២៨
- ការិយាល័យសាខា ........ ៣៤
- ព្រឹត្តិការណ៍សង្ខេបឆ្នាំ២០២០ ........ ៣៦
- ភាពជោគជ័យរបស់អតិថិជន ........ ៤៣

**របាយការណ៍ហិរញ្ញវត្ថុ**
- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ........ ៤៦
- របាយការណ៍របស់សវនករឯករាជ្យ ........ ៤៩
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ........ ៥៣
- របាយការណ៍ចំណូលពេញលេញ ........ ៥៥
- របាយការណ៍បម្រែបម្រួលមូលធន ........ ៥៦
- របាយការណ៍លំហូរសាច់ប្រាក់ ........ ៥៨

# សាររបស់លោកប្រធាន ក្រុមប្រឹក្សាភិបាល



ផ្ដើមចេញពីធនធានដ៏រឹងមាំ និង បែបផែនគ្រប់គ្រងពីប្រទេសកូរ៉េខាងត្បូង ជោគជ័យ ហ្វាយនែន បានបង្ហាញវត្តមានគួរឱ្យកត់សម្គាល់ក្នុងនាមជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ **Hanshin Engineering and Construction Co., Ltd** នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ យើងពិតជាមានការភ្ញាក់ផ្អើលនិងរីករាយយ៉ាងខ្លាំងចំពោះសមិទ្ធផល និងការខិតខំប្រឹងប្រែងដែលត្រូវបានទទួលស្គាល់ដោយនិយ័តករ ជាពិសេសធនាគារជាតិនៃកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដៃគូសហការ និង សាធារណជន។

អ្វីដែលកាន់ពិសេសជាងនេះទៅទៀត ជោគជ័យ ហ្វាយនែន មានសេចក្ដីសោមនស្សរីករាយជាក្រៃលែង ដែលទទួលបានកម្រិតអនុលោមភាពសារពើពន្ធប្រភេទ «មាស» ពីអគ្គនាយកដ្ឋានពន្ធដារ ដែលមានប្រសិទ្ធភាពរយៈពេល២ឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធ ២០២០ ដល់ ២០២១។ សមិទ្ធិផលដ៏ប្រពៃនេះ ទទួលបានមកពីកិច្ចខិតខំប្រឹងប្រែងបំពេញកាតព្វកិច្ច និងការប្តេជ្ញាចិត្តខ្ពស់ដើម្បីធានាថាយើងបានធ្វើស្របតាមបទប្បញ្ញត្តិពន្ធត្រឹមត្រូវ។

ក្នុងរយៈពេល៤ឆ្នាំមកនេះ ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំសូមកោតសរសើរដោយស្មោះ ចំពោះការដឹកនាំរបស់គណៈគ្រប់គ្រងរបស់ជោគជ័យ ដែលបានផ្ដល់ទិសដៅច្បាស់លាស់ដល់បុគ្គលិករបស់យើង ទោះបីជាស្ថិតក្នុងស្ថានភាពដ៏លំបាកនៃការរីករាតត្បាតជម្ងឺកូវីដ-១៩។ តាមរយៈការដឹកនាំ និងការណែនាំរបស់ពួកគាត់ ទើបធ្វើអោយបុគ្គលិករបស់យើង យល់ដឹងពីរបៀបដោះស្រាយបានយ៉ាងល្អទោះបីស្ថិតក្នុងស្ថានភាពណាក៏ដោយ ។

ឆ្នាំ២០២០ បានផ្ដល់នូវលំហាត់ជាសកល សម្រាប់មនុស្សគ្រប់ៗគ្នាមិនថាជាបុគ្គល ឬ ក្រុមហ៊ុនអាជីវកម្មគ្រប់កម្រិត។ យើងពិតជាសំណាងណាស់ ដែលមានគណៈគ្រប់គ្រងដែលចូលរួមយ៉ាងសកម្មក្នុងការត្រិះរិះគិតពិចារណា ដែលតែងតែគិតពីបញ្ហាមុន និងបានរៀបចំយ៉ាងល្អសម្រាប់ដំណោះស្រាយ។

ជំហានដ៏ធំមួយទៀតដែលយើងបានធ្វើ គឺការចាប់ផ្ដើមប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សសម្រាប់ការិយាល័យកណ្ដាល និងគ្រប់សាខាទាំងអស់។ រាល់កិច្ចការដែលធ្លាប់ធ្វើដោយដៃពីមុន ត្រូវបានធ្វើដោយគ្រាន់តែប្រើប្រាស់នូវម្រាមដៃ សម្រាប់ការកត់ត្រាវត្តមាន ការឈប់សម្រាក និង ត្រួតពិនិត្យពីបច្ចុប្បន្នភាពព័ត៌មានរបស់បុគ្គលិក។

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា បានបង្ហាញអំពីកំណើនអវិជ្ជមានបន្តិចបន្តួចនៅឆ្នាំ ២០២០ ប៉ុន្តែតាមរយៈការជួយជ្រោមជ្រែងរបស់រាជរដ្ឋាភិបាល និងផ្នែកផ្សេងទៀត យើងជឿជាក់ថាសេដ្ឋកិច្ច នឹងស្គាល់ភាពលូតលាស់ជាថ្មីក្នុងរង្វង់ ៤ភាគរយ នៅឆ្នាំ២០២១។

# ទស្សនវិស័យ និងយុទ្ធសាស្ត្រសម្រាប់ឆ្នាំ ២០២១

ផ្អែកលើការវិភាគដ៏វិជ្ជមានពីកម្មវិធីអភិវឌ្ឍន៍អាស៊ី កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០២១ ត្រូវបានព្យាករណ៍ថានឹងមានភាពរឹងមាំបំផុតនៅអាស៊ីបូព៌ា និងអាស៊ីខាងត្បូង ហើយមានកម្រិតមធ្យមនៅអាស៊ីកណ្ដាល អាស៊ីអាគ្នេយ៍ និងតំបន់ប៉ាស៊ីហ្វិក។ ផលិតកម្មឧស្សាហកម្មត្រូវបានគេរំពឹងថានឹងកើនឡើង ៧,១% ក្នុងឆ្នាំ២០២១ ដោយសារការងើបឡើងវិញនៃវិស័យកាត់ដេរសម្លៀកបំពាក់ស្បែកជើងនិងទំនិញសម្រាប់ធ្វើដំណើរ ក៏ដូចជាការកើនឡើងនៃផលិតកម្មផុនស្រាលផ្សេងទៀត គ្រឿងអេឡិចត្រូនិច និង យានជំនិះគ្រប់ប្រភេទ ខណៈវិស័យកសិកម្ម និងសេវាកម្មរំពឹងថានឹងកើនឡើងត្រឹមតែ ១,៣% និង ៣,៣% នៅក្នុងឆ្នាំ ២០២១។

ដើម្បីត្រៀមខ្លួន ក្នុងការវិលត្រឡប់មករកស្ថានភាពដើមនៃសេដ្ឋកិច្ចវិញ ជោគជ័យ ប្ដេជ្ញាថានឹងបង្កើនឲ្យមានប្រសិទ្ធិភាពជាងមុនទាក់ទងនឹងប្រតិបត្តិការ ដោយដាក់ចេញឲ្យប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ បន្តផ្តល់សេវាកម្មលឿនបំផុត និង បង្កើនអត្ថប្រយោជន៍បន្ថែម ដូចអ្វីដែលបានចែងក្នុងពាក្យស្លោករបស់យើងថា ″ ជម្រើសប្រសើរបំផុតដើម្បីជោគជ័យ ″ ។

ដោយមានការតាំងចិត្តខ្ពស់ ក្នុងការឈរនៅលំដាប់កំពូលក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ផ្អែកលើប្រាក់កម្ចី និង កេរ្តិ៍ឈ្មោះល្អ យើងតែងតែស្វែងរកដំណោះស្រាយដែលមានប្រសិទ្ធិភាពបំផុត ដែលអាចជួយសម្រួលបញ្ហា ឬ តម្រូវការរបស់ប្រជាជនកម្ពុជា។ការផ្ដោតសំខាន់របស់យើងក្នុងការអភិវឌ្ឍផលិតផល គឺការបន្តពង្រីកវិសាលភាពផលិតផលសេវាកម្មរបស់យើង ពីលក្ខណៈបុគ្គលទៅក្រុមហ៊ុន (អាជីវកម្មទៅអាជីវកម្ម) និង អាចរួមបញ្ចូលទាំងផលិតផលបែបឌីជីថល ឬបច្ចេកវិទ្យាផងដែរ។

អ្វីដែរសំខាន់ផងដែរនោះ ខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅដល់សមាជិកក្រុមប្រឹក្សាភិបាល អគ្គនាយក ថ្នាក់ដឹកនាំកំពូលៗ និងបុគ្គលិកទាំងអស់របស់ ជោគជ័យ ដែលបានចូលរួមយ៉ាងខ្លាំងក្លាដើម្បីសម្រេចនូវសមិទ្ធផលល្អៗ សម្រាប់ក្រុមហ៊ុនរបស់យើង។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់អាជ្ញាធរ អ្នកពាក់ព័ន្ធ អតិថិជន ដៃគូ និងសហគមន៍មូលដ្ឋាន សម្រាប់ការជួយសម្របសម្រួល ជាប្រចាំ ក្នុងការជួយឲ្យយើងខិតជិតទៅរកគោលដៅរបស់យើង ក្នុងការកសាងស្ថាប័នហិរញ្ញវត្ថុលំដាប់ពិភពលោក។ ខ្ញុំសូមគោរពនិងថ្លែងអំណរអរគុណចំពោះធនាគារជាតិនៃកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាដែលបានជួយផ្តល់ការណែនាំ និងជួយជ្រោមជ្រែងយ៉ាងស្វាហាប់តាំងពីមុនពេលមានការរីករាលដាលនៃជំងឺរាតត្បាតនេះមកម្លេះ។ ដើម្បីជំនះស្ថានការណ៍បច្ចុប្បន្ននេះ ខ្ញុំសង្ឃឹមថានឹងបន្តមានការចូលរួមចំណែកយ៉ាងរឹងមាំនិងប្រកបដោយផ្លែផ្កាពីអ្នកទាំងអស់គ្នាតទៅទៀត។

**លោក MOON KYU CHOI**
ប្រធានក្រុមប្រឹក្សាភិបាល

# សាររបស់លោកអគ្គនាយក

ជាង៥ឆ្នាំកន្លងមកនេះ ជោគជ័យ ពិតជាទទួលបានសមិទ្ធផលដ៏គួរឲ្យកត់សម្គាល់យ៉ាងខ្លាំង ជាពិសេសបន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណជាផ្លូវការពីធនាគារជាតិនៃកម្ពុជា ក្នុងការផ្ទេរកម្មសិទ្ធិពីស្ថាបនិកខ្មែរមកកាន់ម្ចាស់ភាគហ៊ុនជនជាតិកូរ៉េ នៅខែសីហាឆ្នាំ២០១៧។គិតត្រឹមខែធ្នូឆ្នាំ២០២០ជោគជ័យបានផ្ដល់ឱកាសដល់ធនធានមនុស្សដែលមានសក្ដានុពលចំនួន ២៥២នាក់ ឲ្យចូលបម្រើការនៅទីស្នាក់ការកណ្ដាល និងសាខាប្រត្តិបត្តិការចំនួន ០៨ ជាមួយនឹងផលប័ត្រប្រាក់កម្ចីជាង ៣១ លានដុល្លារ និង មានអតិថិជនចំនួន ៧,២៤៨នាក់។



ទោះបីជាការផ្ទុះឡើងនៃជម្ងឺកូវីដ-១៩ បានផ្ដល់ផលប៉ះពាល់យ៉ាងខ្លាំង ចាប់តាំងពីដើមឆ្នាំ២០២០ យើងនៅតែបន្តមើលឃើញពីកំណើននៃផលប័ត្រប្រាក់កម្ចីនៅក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជាដែលរួមបញ្ចូលគ្នា រវាងគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ(MFIs) បានកើនឡើង ១៤,៨% ប្រមាណ ៣៧,៣ ពាន់លានដុល្លារក្នុងឆ្នាំ២០២០នេះ។

ជោគជ័យ ជាផ្នែកមួយនៃភាពរីកចម្រើន បច្ចុប្បន្ននេះសម្រាប់ប្រទេសកម្ពុជាដោយសារតែយើងមានធនធានមនុស្សប្រកដោយសក្ដានុពលខ្ពស់ ជាពិសេសគណៈគ្រប់គ្រងប្រកបដោយគតិបណ្ឌិត ក្រុមការងារផ្នែកប្រតិបត្តិការជំសកម្ម និង ក្រុមការងារផ្នែកលក់ពោរពេញដោយសមត្ថភាព។ ពួកគាត់គឺចលករដ៏សំខាន់ ក្នុងការចូលរួមចំណែកឥតឈប់ឈរ ដើម្បីសម្រេចគោលដៅស្ថាប័នយើងនិងរក្សាភាពប្រកួតប្រជែងនៅក្នុងវិស័យហិរញ្ញវត្ថុ។

អាថ៌កំបាំងនៅពីក្រោយធនធាន ដែលមានសមត្ថភាពរបស់ជោគជ័យ គឺយើងជាជម្រកដែលពោរពេញទៅដោយជំនាញពិតប្រាកដ និង ទស្សនវិស័យផ្សេងគ្នាៗ ដែលធ្វើឲ្យយើងបង្កើតបានគំនិតជាច្រើនប្រកបដោយផ្លែផ្កា។ ការអនុវត្តន៏របស់យើងគឺ ថែរក្សា និងទាក់ទាញបុគ្គលដែលមានគំនិតច្នៃប្រឌិតខ្ពស់ការប្ដេជ្ញា និងជាបុគ្គលដែលសកម្មក្នុងការចូលរួមជួយដោះស្រាយបញ្ហា។ អ្វីដែលគួរឲ្យកត់សម្គាល់ផងដែរនោះ ភាពលេចធ្លោរបស់យើងគឺការផ្ដល់ជូនសេវាកម្មរហ័សបំផុត និងការពិគ្រោះយោបល់ផ្នែកហិរញ្ញវត្ថុដោយស្មោះត្រង់ ដើម្បីជួយអតិថិជនបំពេញតម្រូវការទាន់ពេលវេលា និង ដើម្បីមនុស្សជាទីស្រលាញ់របស់ពួកគេ។

បញ្ហាប្រឈមដែលមិនអាចដឹងមុនដូចជាជម្ងឺកូវីដ-១៩ និង ការដាក់របាំង នៃផលិតផលនាំចូលមួយចំនួនទៅកាន់ទីផ្សារអឺរ៉ុប " អ្វីៗទាំងអស់លើកលែងតែអាវុធ " បាននាំមកនូវផលប៉ះពាល់មួយចំនួនដល់ប្រទេសកម្ពុជា ជាពិសេសវិស័យទេសចរណ៍ ផលិតកម្មនាំចេញ និងឧស្សាហកម្មសំណង់។ ទោះបីយ៉ាងណាក៏ដោយ ចំពោះបញ្ហាប្រឈមនៃជម្ងឺកូវីដ-១៩ នេះ យើងសង្កេតឃើញថា រាជរដ្ឋាភិបាលបានចាត់វិធានការបង្ការយ៉ាងតឹងរឹង និង បានរក្សាទុកនូវឧបករណ៍ពេទ្យមួយចំនួន ដើម្បីរួចផុតពីវិបត្តិនេះ។ ជាមួយនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ជំនួយសង្គម និង ការគ្រាំទ្រហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យម យើងរំពឹងថាកំណើន ផលិតផលក្នុងស្រុកសរុបអាចនឹងស្ទុះឡើងដល់ ៥,៩ ភាគរយនៅឆ្នាំ ២០២១។

" គម្រោងផែនការធំបែបផែនណាក៏ដោយ អ្វីដែលសំខាន់នោះគឺការចាប់ផ្ដើមសកម្មភាពការងារ "។ យើងពិតជាកោតសរសើរយ៉ាងខ្លាំង ចំពោះការផ្លាស់ប្ដូរដ៏អស្ចារ្យរបស់យើង ក្នុងការទទួលយកប្រព័ន្ធគ្រប់គ្រងធនធានមនុស្សសម្រាប់បុគ្គលិក ក្នុងកំឡុងពេលនៃការរក្សាគន្លាតសង្គមនេះ។ នៅឆ្នាំ២០២១ខាងមុខនេះ យើងទន្ទឹងរង់ចាំការបង្កើតនូវផលិតផលសេវាកម្មថ្មីៗ ដែលប្រកបដោយគំនិតច្នៃប្រឌិតខ្ពស់ ការបើកដំណើរការជាផ្លូវការនូវកម្មវិធីទូរស័ព្ទដៃរបស់យើង និង កម្មវិធីជួបជុំនិងបង្កើតភាពស្និទ្ធស្នាលសម្រាប់បុគ្គលិក។ ក្នុងនាមជាថ្នាក់ដឹកនាំរបស់ជោគជ័យ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អតិថិជន និង ដៃគូរសហការក្នុងការគាំទ្រនិងជ្រោមជ្រែងយ៉ាងស្អិតរម្មួតកន្លងមក។

សូមថែរក្សាសុខភាព និងសុវត្ថិភាពឲ្យបានល្អ!



**លោក CHEON GIL PARK**
អគ្គនាយក

# អំពីជោគជ័យ



## ប្រវត្តិសង្ខេបរបស់ជោគជ័យ

**២០១៦**

អាជ្ញាបណ្ណប្រកបអាជីវកម្ម ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពី ធនាគារជាតិនៃកម្ពុជា (ខែមេសា)

**២០១៧**

ត្រូវបានទិញដោយក្រុមហ៊ុន កូរ៉េ ២គឺ **Hanshin E&C** និង **Plus International** (ខែសីហា)

**២០១៨**

- ខែមីនា ពង្រីក ៣សាខាថ្មី(ទួលគោក តាខ្មៅ និងថ្នល់ទទឹង)
- ខែកក្កដា ពង្រីក ២សាខាថ្មី(កំពង់ស្ពឺ និងជើងព្រៃ)

**២០១៩**

ផ្លាស់ប្តូរការប្រើប្រាស់ Core-banking ថ្មី “**Apsara**”(ខែឧសភា)

**២០២០**

- ខែតុលា ពង្រីក ២សាខាថ្មី(គងពិសី និងសាខាកំពង់ត្រឡាច)
- ដាក់ឲ្យដំណើរការផលិតផលថ្មី (កម្ចីអេឡិចត្រូនិច)

# ភាគទុនិក

ក្រុមហ៊ុន Hanshin E&C Co.,Ltd






ក្រុមហ៊ុន Plus International Co., Ltd

## គម្រោងសំណង់ធំៗរបស់ក្រុមហ៊ុន HANSHIN E&C ក្នុងឆ្នាំ ២០២០







## គម្រោងសាងសង់ផ្លូវជាតិលេខ ២ និងផ្លូវជាតិលេខ ៥ ក្នុងប្រទេសកម្ពុជា









ជោគជ័យ ហ្វាយនែន

និមិត្តសញ្ញារបស់ ជោគជ័យ ត្រូវបាន
គូសចេញពី " ទូកប្រណាំងខ្មែរ "

## ចក្ខុវិស័យ

យើងខិតខំប្រឹងប្រែង ដើម្បីក្លាយជាក្រុមហ៊ុនហិរញ្ញវត្ថុលំដាប់ពិភពលោក " **វិសាលភាពលុបលើវិស័យធនាគារ** " ទាំងលើទំហំផលចំណេញ និង " **ការទទួលស្គាល់លើកិត្យានុភាព** " (ភាពជឿជាក់  ភាពងាយស្រួល និងល្បឿននៃសេវាកម្ម)  និង " **ការបំពេញចិត្ត ដល់បុគ្គលិកគ្រប់ជាន់ថ្នាក់** " ។

## បេសកកម្ម

**ទទួលបាននូវភក្តីភាពយូរអង្វែងពីសំណាក់អតិថិជន** គោលដៅស្ថិតក្នុងជីវភាពទាបនិងមធ្យមតាមរយៈការផ្តល់កម្ចីនិងសេវាកម្មហិរញ្ញវត្ថុដើម្បីជួយលើកកម្ពស់ **ការរីកចម្រើននៃអាជីវកម្មប្រកបដោយនិរន្តរភាព** ព្រមទាំងរួមចំណែកបង្កើតនូវ " **វប្បធម៌នៃទម្លាប់ជោគជ័យ** " សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។

## វប្បធម៌

ជា **ស្ថាប័នប្រកបដោយសក្តានុពល** យើងមាន **ចក្ខុវិស័យរួមជាសកល** ដើម្បីប្រែក្លាយជាក្រុមហ៊ុនលំដាប់ថ្នាក់ពិភពលោកដោយឈរលើមូលដ្ឋាន **ទម្លាប់នៃការបង្កើតភាពជោគជ័យ** និងការអភិវឌ្ឍន៍សម្រាប់ **ការផ្លាស់ប្តូរវិជ្ជមាន**។ យើងទាំងអស់គ្នាប្រឹងប្រែងដើម្បីការរីកចម្រើនរួមគ្នា និង **ផ្តល់ភាពរីករាយ** សម្រាប់ជីវិតឯកជនរបស់យើង។ យើងទាំងអស់គ្នាគឺគ្រួសារជោគជ័យ ហ្វាយនែន។

## ទស្សនៈវិស័យ

- **ការផ្តល់តម្លៃបុគ្គលិកជាធំ**
- ភាពស្មោះត្រង់
- ចេះទទួលយកវប្បធម៌ការងារល្អ
- ការគោរពតួនាទីរៀងៗខ្លួន
- អព្យាក្រឹតភាព

# រចនាសម្ព័ន្ធគ្រឹះស្ថាន



# ក្រុមប្រឹក្សាភិបាល



### លោក Choi, Moon Kyu
ប្រធានក្រុមប្រឹក្សាភិបាល

- បច្ចុប្បន្នជាអគ្គនាយកក្រុមហ៊ុន Hanshin E&C
- បរិញ្ញាបត្រជាន់ខ្ពស់ពី Thunderbird School of Global Management, Arizona, USA
- បរិញ្ញាបត្រពី Sogang University, Seoul, Korea
- បុគ្គលិកក្រុមហ៊ុន Hyundai Merchant Marine & Hyundai Motor Company



### លោក Kim, Jung Hoon
អភិបាលឯករាជ្យ

- បច្ចុប្បន្នជា នាយកនាយកដ្ឋានហិរញ្ញវត្ថុ ក្រុមហ៊ុន Success Promise Co., Ltd.
- បរិញ្ញាបត្រផ្នែកពាណិជ្ជកម្មពី Sogang University, Seoul, Korea
- បុគ្គលិកក្រុមហ៊ុន Hyundai Marine & Fire Insurance



### លោក Park, Cheon Gil
អភិបាល និងអគ្គនាយក

- ធ្លាប់កាន់តំណែងជា អគ្គនាយក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ Green Central
- ប្រធានគ្រប់គ្រងក្រុមហ៊ុន Samsung Card, Seoul, Korea
- ប្រធានក្រុមការងារក្រុមហ៊ុន Hyundai Card, Seoul, Korea
- នាយកនាយកដ្ឋានទីផ្សារនៃក្រុមហ៊ុន CJ Hello, Seoul, Korea
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម YONSEI University(2011), Seoul Korea
- វិញ្ញាបនប័ត្រផ្នែក Extension Marketing(2004) ពី UC Berkeley, California USA
- បរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម Sogang University(1998), Seoul Korea

# គណៈគ្រប់គ្រង



### លោក ចេង ប៊ុនធឿន
នាយកប្រតិបត្តិការ

- បទពិសោធន៍ការងារជាង ១២ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីគ្រប់គ្រងហានិភ័យ អនុប្រធានផ្នែកកម្ចី ប្រធានផ្នែកគ្រប់គ្រងហានិភ័យ នាយករងប្រតិបត្តិ នាយកនាយកដ្ឋានឥណទាន និង នាយក នាយកដ្ឋាននីតិកម្ម និងប្រតិបត្តិតាម
- បរិញ្ញាបត្រផ្នែកអភិវឌ្ឍសេដ្ឋកិច្ច (២០០៧) និង អនុបណ្ឌិតផ្នែករដ្ឋបាលសាធារណៈ (២០១៦)



### លោក Kim Keongu
ប្រធាននាយក នាយកដ្ឋានផែនការ

- បទពិសោធន៍ជាង ១៣ឆ្នាំ ក្នុងផ្នែកគណនេយ្យ (ប្រទេសកូរ៉េខាងត្បូង អាស៊ីអាគ្នេយ៍ មជ្ឈឹមបូព៌ា)
- ធ្លាប់កាន់តំណែងជាប្រធានផ្នែកហិរញ្ញវត្ថុនៃក្រុមហ៊ុន Hanshin Engineering and Construction Co.,Ltd
- បរិញ្ញាបត្រផ្នែកគណនេយ្យនិងប្រព័ន្ធព័ត៌មាន (២០០៧)



### លោក មួ អេង
ប្រធាននាយក នាយកដ្ឋានអភិវឌ្ឍន៍ផលិតផល

- បទពិសោធន៍ការងារជាង ១២ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុមីក្រូហិរញ្ញវត្ថុ និងហាងបញ្ចាំ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីបណ្តុះបណ្តាល ប្រធានផ្នែកបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ មន្ត្រីអភិវឌ្ឍន៍ផលិតផល មន្ត្រីអភិវឌ្ឍន៍អាជីវកម្ម ប្រធានសាខា និងប្រធានផ្នែកប្រតិបត្តិការ
- បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រអប់រំនិងគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ



## លោក អ៊ុក តូរ៉ាគ្លីត
ប្រធាននាយក នាយកដ្ឋាន
ហិរញ្ញវត្ថុ និងរតនាគារ

- បទពិសោធន៍ការងារជាង ៥ឆ្នាំនៅក្រុមហ៊ុនសវនកម្មខេភីអឹមជី (កម្ពុជា) ដែលធ្វើការផ្ទាល់ជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុ សាជីវកម្មសណ្ឋាគារ និង អង្គការក្រៅរាជរដ្ឋាភិបាល
- ធ្លាប់កាន់តំណែងជា ប្រធានផ្នែកហិរញ្ញវត្ថុ និងនាយករង នាយកដ្ឋានហិរញ្ញវត្ថុ
- កំពុងបន្តការសិក្សាផ្នែក ACCA
- បរិញ្ញាបត្រផ្នែកគណនេយ្យ (២០១២)



## លោក ហំ សំណាង
ប្រធាននាយក នាយកដ្ឋាន
ព័ត៌មានវិទ្យា

- បទពិសោធន៍ការងារជាង ៥ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ  និង ៦ឆ្នាំនៅក្នុងវិស័យឯកជន
- ធ្លាប់កាន់តំណែងជាអ្នកសរសេរកម្មវិធីព័ត៌មានវិទ្យា អ្នកអភិវឌ្ឍន៍កម្មវិធីជាន់ខ្ពស់ ប្រធានផ្នែកគាំទ្រអតិថិជន ប្រធានផ្នែកប្រព័ន្ធគ្រប់គ្រងព័ត៌មាន អនុប្រធានផ្នែកព័ត៌មានវិទ្យា
- បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ



## លោក លឹម រតនៈ
នាយក នាយកដ្ឋាន ប្រតិបត្តិការទី១

- បទពិសោធន៍ជាង ១១ឆ្នាំនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទានប្រតិបត្តិករ មន្ត្រីឥណទាន ប្រធានក្រុមនាយកសាខា និង ប្រធានផ្នែកហានិភ័យឥណទាន
- បរិញ្ញាបត្រផ្នែកអភិវឌ្ឍជនបទ (២០១១)



## លោក ឈន វ៉ារី
នាយក នាយកដ្ឋាន ប្រតិបត្តិការទី២

- បទពិសោធន៍ការងារជាង ៩ឆ្នាំក្នុងវិស័យធនាគារ និង មីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា អ្នកគ្រប់គ្រងឥណទាន ប្រធានគ្រប់គ្រងការផ្តល់ប្រាក់កម្ចីសហគ្រាសខ្នាតតូចនិងមធ្យម អនុប្រធានសាខាទូទៅ ប្រធានផ្នែកទំនាក់ទំនង មន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនង និងមន្ត្រីឥណទាន
- បរិញ្ញាបត្រផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ (២០១២)



## លោក ណែម ម៉ានៀន
នាយក នាយកដ្ឋាន
គ្រប់គ្រង ហានិភ័យឥណទាន

- បទពិសោធន៍ការងារជាង ៨ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជាមន្ត្រីឥណទាន មន្ត្រីគ្រប់គ្រងឥណទានជាន់ខ្ពស់ នាយកសាខា ជំនួយការនាយកនាយកដ្ឋាន
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកធុរកិច្ចរដ្ឋបាល (២០១៥)



## លោក ដួង សត្យា
### នាយក នាយកដ្ឋានអាជីវកម្ម

- បទពិសោធន៍ការងារជាង១១ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីដោះស្រាយបំណុល នាយកសាខាជាន់ខ្ពស់ គ្រូបង្វឹក នាយករងប្រចាំសាខា ប្រធានផ្នែកឥណទាន និងដោះស្រាយបំណុល ប្រធានប្រចាំតំបន់
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកធុរកិច្ចពាណិជ្ជកម្ម (២០១៣)



## លោកស្រី ពេជ្រ សូរិយា
### នាយិកា នាយកដ្ឋានហិរញ្ញវត្ថុ

- បទពិសោធន៍ការងារជាង ៦ ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារឯកទេស
- ធ្លាប់កាន់តំណែងជា បេឡាធិការ ប្រធានគណនេយ្យ មន្ត្រីគាំទ្រគណនេយ្យ ប្រធានផ្នែកគាំទ្រគណនេយ្យ និង នាយិការង នាយកដ្ឋានហិរញ្ញវត្ថុ
- បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារ (២០១៤)



## លោក ហាន ច័ន្ទជំនោ
### នាយក នាយកដ្ឋាន នីតិកម្ម និងប្រតិបត្តិតាម

- ធ្លាប់ជាអ្នកបកប្រែជាន់ខ្ពស់ បកប្រែផ្ទាល់មាត់ និងប្រធានផ្នែកត្រួតពិនិត្យគុណភាព និងនាយកសាខាគ្រឹះស្ថានអប់រំ
- បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច (២០១១) និងបរិញ្ញាបត្រផ្នែកអប់រំ (២០១២)



## លោក អ៊ុន សេងទ្រឿ
### នាយករង នាយកដ្ឋានសវនកម្មផ្ទៃក្នុង

- បទពិសោធន៍ការងារជាង ៩ ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជាមន្ត្រីឥណទាន មន្ត្រីឥណទានជាន់ខ្ពស់ មន្ត្រីសវនកម្មផ្ទៃក្នុង មន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់  ប្រធានគ្រប់គ្រងផ្នែកសវនកម្មផ្ទៃក្នុង
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ និងធនាគារ (២០១៦)



## លោក ឈូ សុខលាភ
### នាយករង នាយកដ្ឋាន ដោះស្រាយបំណុល

- បទពិសោធន៍ការងារជាង ១១ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជាមន្ត្រីបម្រើសេវាអតិថិជន មន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន ប្រធានសាខា និង ប្រធានផ្នែកសវនកម្មផ្ទៃក្នុង
- បរិញ្ញាបត្រ និង បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ និងធនាគារ



## កញ្ញា តារា រតនៈរស្មី
### នាយិការង នាយកដ្ឋាន ធនធានមនុស្ស និង ទីផ្សារ

- បទពិសោធន៏ការងារជាង ៤ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុ មជ្ឈមណ្ឌលបណ្តុះបណ្តាល និង ពាណិជ្ជកម្មអេឡិចត្រូនិច
- ធ្លាប់កាន់តំណែងជា លេខាធិការ មន្ត្រីផ្នែកទីផ្សារនិងទំនាក់ទំនង មន្ត្រីប្រឹក្សាផ្នែកទីផ្សារ និង ប្រធានផ្នែកទីផ្សារ
- បរិញ្ញាបត្រផ្នែកធុរកិច្ចពាណិជ្ជកម្ម (២០១៥) បរិញ្ញាបត្រផ្នែកអក្សរសាស្ត្រភាសាអង់គ្លេស (២០១៧) និង បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកធុរកិច្ចពាណិជ្ជកម្មសកល (២០១៩)



## លោក ម៉ុន រស្មី

**នាយករង នាយកដ្ឋាន គ្រប់គ្រងទ្រព្យសម្បត្តិ**

- បទពិសោធន៍ការងារជាង ៨ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជាមន្ត្រីឥណទាន មន្ត្រីរដ្ឋបាល មន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងប្រធានផ្នែករដ្ឋបាល
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកធុរកិច្ចរដ្ឋបាល (២០១៩)



## លោកស្រី ស៊ិន ស្រីល័ក្ខ

**នាយិកាស្តីទី នាយកដ្ឋាន ផែនការធនធានមនុស្ស**

- បទពិសោធន៍ការងារជាង ៧ឆ្នាំក្នុងវិស័យរោងចក្រ និង ៤ឆ្នាំក្នុងវិស័យឯកជន
- ធ្លាប់កាន់តំណែងជា គ្រូភាសាអង់គ្លេស ជំនួយការគណនេយ្យ អ្នកគ្រប់គ្រងធនធានមនុស្សនិងចាត់ការទូទៅ និង ប្រធានផ្នែកមន្ត្រីគ្រប់គ្រងការងារបុគ្គលិក
- បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុនិងធនាគារ (២០១៣)



## លោក ញិល ធារុទ្ធ

**នាយករង នាយកដ្ឋាន ព័ត៌មានវិទ្យា**

- បទពិសោធន៏ការងារជាង ៧ឆ្នាំក្នុងការអភិវឌ្ឍន៏ប្រព័ន្ធធនាគារស្នូល ប្រព័ន្ធគ្រប់គ្រងមន្ទីរពេទ្យ និងប្រព័ន្ធគ្រប់គ្រងផ្នែកធនធានមនុស្ស
- បរិញ្ញាបត្រផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មាន (២០១៣)



## លោក នៅ គីមឡាយ

**នាយករង នាយកដ្ឋានផែនការ**

- បទពិសោធន៍ការងារជាង ១១ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុជាន់ខ្ពស់  មន្ត្រីរបាយការណ៍បទបញ្ញត្តិជាន់ខ្ពស់ និង ប្រធានផ្នែករតនាភិបាល
- កំពុងបន្តការសិក្សាផ្នែក ACCA
- បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុនិងធនាគារ (២០១០)

# សមិទ្ធផលអាជីវកម្ម ឆ្នាំ២០២០

## ប្រភពទុនវិនិយោគ

PPCBank
KB Kookmin Bank
Industrial Bank of Korea
KDB Bank

## ដៃគូសហការ

true money
Wing
HYUNDAI
CAMKO MOTOR COMPANY LTD
Hyundai Official Distrutor in Cambodia

## យើងមានមោទនភាពជាខ្លាំងក្នុងការជាសមាជិកនៃ

EUROCHAM CAMBODIA
THE KOREAN CHAMBER OF COMMERCE IN CAMBODIA KOCHAM



# តារាងសង្ខេបលទ្ធផលឆ្នាំ ២០២០

សមតុល្យផលប័ត្រឥណទានសរុប

(គិតជាដុល្លារអាមេរិក)




ទ្រព្យសកម្មសរុប

(គិតជាដុល្លារអាមេរិក)




ចំនួនគណនីអតិថិជន




ចំនួនសាខាប្រតិបត្តិការ



> ជោគជ័យ ហ្វាយនែន មានសេចក្ដីសោមនស្សរីករាយនិងកិត្តិយសជាក្រៃលែងដែលទទួលបានកម្រិតអនុលោមភាព **សារពើពន្ធប្រភេទ " មាស "** ពី អគ្គនាយកដ្ឋានពន្ធដារ ដែលមានប្រសិទ្ធភាពរយៈពេល ២ឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធ ២០២០ ដល់ ២០២១




# ទំនើបកម្មនៃការប្រើប្រាស់ប្រព័ន្ធឌីជីថល



# ផលិតផលកម្ចី







## កម្ចីទូទៅ

ប្រភេទកម្ចីដើម្បីគាំទ្រដល់លំហូរសាច់ប្រាក់នៃការចំណាយក្នុងគ្រួសារឬការវិនិយោគប្រភេទណាមួយ។ វាអាចត្រូវបានប្រើប្រាស់សម្រាប់ការទិញដី ជួសជុល ឬទិញផ្ទះ បើកដំណើរការ ឬពង្រីកអាជីវកម្ម និងការចំណាយចាំបាច់សម្រាប់គ្រួសារជាទីស្រឡាញ់របស់ពួកគេ។

| | |
|---|---|
| ទំហំកម្ចី | ធំជាង ៣.០០០ រហូតដល់ ៣០.០០០ដុល្លារអាមេរិក ឬរូបិយប័ណ្ណសមមូល |
| រយៈពេលកម្ចី | រហូតដល់ ៧២ខែ |
| របៀបបង់សង | សងរំលោះប្រាក់ដើមនិងការប្រាក់ប្រចាំខែ សងការប្រាក់និងប្រាក់ដើមថេរប្រចាំខែ សងការប្រាក់និងប្រាក់ដើមតាមដំណាក់កាល សងរំលោះប្រាក់ដើមតាមការចរចា សងការប្រាក់រៀងរាល់ខែនិងប្រាក់ដើមនៅចុងវគ្គ |
| រូបិយប័ណ្ណ | ប្រាក់រៀល ដុល្លារអាមេរិក |

## កម្ចីកសិកម្ម

គោលបំណងនៃការប្រើប្រាស់គឺដើម្បីផ្តល់ដើមទុនដល់អតិថិជនក្នុងការវិនិយោគលើគ្រាប់ពូជរុក្ខជាតិឧបករណ៍កសិកម្មធុន់ៗ ឬ ទិញដីសម្រាប់សកម្មភាពដាំដុះកសិកម្ម។

| | |
|---|---|
| ទំហំកម្ចី | រហូតដល់ ១៥.០០០ដុល្លារ ឬរូបិយប័ណ្ណសមមូល |
| រយៈពេលកម្ចី | រហូតដល់ ៦០ខែ |
| របៀបបង់សង | បង់ប្រាក់ដើមនៅចុងវគ្គ និងការប្រាក់ប្រចាំខែ បង់ប្រាក់ដើមរំលស់ថេរ និង ការប្រាក់ប្រចាំខែ បង់ប្រាក់ដើម និងការប្រាក់ រំលស់ថេរប្រចាំ |
| រូបិយប័ណ្ណ | ប្រាក់រៀល ដុល្លារអាមេរិក |







## កម្ចីទាន់ចិត្ត

កញ្ចប់នៃប្រភេទកម្ចីពិសេសមួយសម្រាប់តម្រូវការបន្ទាន់ក្នុងការប្រើប្រាស់ទូទៅសម្រាប់ខ្លួនឯងផ្ទាល់ឬក្រុមគ្រួសារ។សេវាកម្មនេះនឹងផ្តល់លំហូរសាច់ប្រាក់ងាយស្រួលនិងរហ័សទាន់ចិត្តដល់ដៃអតិថិជន។

| | |
|---|---|
| ទំហំកម្ចី | រហូតដល់ ១០.០០០ ដុល្លារអាមេរិក ឬ រូបិយប័ណ្ណសមមូល |
| រយៈពេលកម្ចី | រហូតដល់ ៣៦ខែ |
| របៀបបង់សង | បង់ប្រាក់ដើមរំលស់ថេរ និងការប្រាក់ប្រចាំខែ<br>បង់ប្រាក់ដើម និងការប្រាក់រំលស់ថេរប្រចាំខែ |
| រូបិយប័ណ្ណ | ប្រាក់រៀល ដុល្លារអាមេរិក |

## កម្ចីយានយន្ត

ដើម្បីនាំមកនូវការរស់នៅប្រកបដោយផាសុកភាពសម្រាប់ប្រជាពលរដ្ឋខ្មែរ  ផលិតផលនេះត្រូវបានរចនាឡើងសម្រាប់ជាជំនួយថវិការក្នុងការទិញយានជំនិះដែលសមនឹងជីវភាពរបស់ពួកគេជាមួយនឹងប្រាក់តម្កល់អប្បបរមា ១០ភាគរយ។

| | |
|---|---|
| ទំហំកម្ចី | ១.៥០០ រហូតដល់ ៥០.០០០ ដុល្លារ |
| រយៈពេលកម្ចី | រហូតដល់ ៦០ ខែ |
| របៀបបង់សង | បង់ប្រាក់ដើម និងការប្រាក់រំលស់ថេរប្រចាំខែ |
| រូបិយប័ណ្ណ | ប្រាក់ដុល្លារអាមេរិក |




## កម្ចីអេសអឹមអ៊ី

ឥណទាននេះត្រូវបានបង្កើតឡើងសម្រាប់អតិថិជនដែលកំពុងស្វែងរកការចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនរួមមានផលិតផល សេវាកម្ម សិប្បកម្ម សំណង់ និង ផលិតផលជាច្រើនទៀត។

| | |
|---|---|
| ទំហំកម្ចី | ធំជាង ៣០.០០០ ដល់ ១០០.០០០ ដុល្លារអាមេរិក |
| រយៈពេលកម្ចី | ចាប់ពី១២ខែ ដល់ ១២០ខែ ទៅតាមលទ្ធភាពសង និងគោលបំណងខ្ចីប្រាក់របស់អតិថិជន |
| របៀបបង់សង | បង់ប្រាក់ដើមនៅចុងវគ្គ និងការប្រាក់ប្រចាំខែ<br>បង់ប្រាក់ដើមរំលស់ថេរ និងការប្រាក់ប្រចាំខែ<br>បង់ការប្រាក់ប្រចាំខែ និងប្រាក់ដើមតាមការចរចា |
| រូបិយប័ណ្ណ | ប្រាក់ដុល្លារអាមេរិក |




## កម្ចីអេឡិចត្រូនិច

ដើម្បីបំពេញតំរូវការអ្នកប្រើប្រាស់ទូរស័ព្ទ និងឧបករណ៍អេឡិចត្រូនិច ផលិតផលនេះ ត្រូវបានបង្កើតឡើងដោយមានការសហការគ្នារវាង ជោគជ័យ និងហាងលក់ទូរស័ព្ទ ឬ ហាងអេឡិចត្រូនិច។

| | |
|---|---|
| ទំហំកម្ចី | រហូតដល់ ៥០០ ដុល្លារអាមេរិក ឬ រូបិយប័ណ្ណសមមូល |
| រយៈពេលកម្ចី | ចាប់ពី ០៦ខែ ដល់ ១២ខែ |
| របៀបបង់សង | បង់ប្រាក់ដើម និងការប្រាក់រំលស់ថេរប្រចាំខែ |
| រូបិយប័ណ្ណ | ប្រាក់រៀល ដុល្លារអាមេរិក |

# ការិយាល័យ សាខាប្រតិបត្តិការ







### ១. ការិយាល័យកណ្ដាល និងសាខាស្ទឹងមានជ័យ

ផ្ទះលេខ ៩-១១ ផ្លូវវែងស្រេង សង្កាត់ស្ទឹងមានជ័យ ៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ២០៤ ៣៣៣

### ២. សាខាសែនសុខ

ផ្ទះលេខ P០១៥ ផ្លូវហាណូយ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៣៦៧ ៣៣៣

### ៣. សាខាតាខ្មៅ

ផ្លូវលេខ ១១៥ ភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៤១៨ ៣៣៣

### ៤. សាខាថ្នល់ទទឹង

ផ្លូវជាតិលេខ ៤ ភូមិព្រៃគុយ ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៤៦២ ៣៣៣

### ៥. សាខាកំពង់ស្ពឺ

ភូមិអង្គសេរី សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៤៩៦ ៣៣៣

### ៦. សាខាជើងព្រៃ

ភូមិស្គន់ ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៣២៩ ៣៣៣

### ៧. សាខាគងពិសី

ផ្លូវជាតិលេខ ៣ ភូមិក្របីត្រាំ ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ
លេខទូរស័ព្ទ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ២០៩ ៣៣៣

### ៨. សាខាកំពង់ត្រឡាច

ភូមិច្រករមៀត ឃុំឈូកស ស្រុកកំពង់តឡាច ខេត្តកំពង់ឆ្នាំង
លេខទូរស័ព្ទ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៨៤២ ៣៣៣

# ព្រឹត្តិការណ៍សង្ខេបឆ្នាំ២០២០



“ សិក្ខាសាលាធនធានមនុស្ស ”



“ ទិវាវប្បធម៌ស្ត្រី ”









“ សិក្ខាសាលាគណៈគ្រប់គ្រងប្រចាំឆ្នាំ ”









“ វគ្គបណ្ដុះបណ្ដាលស្ដីពី
Strategic Marketing and Creative Branding in
Financial Institutions ដែលបង្រៀនដោយលោកអគ្គនាយក ”



❝ សិក្ខាសាលាផែនការយុទ្ធសាស្ត្រឆ្នាំ២០២១ ❞







❝ ពិព័រណ៍ការងារឆ្នាំ ២០២០ ❞








“ សកម្មភាពផ្តល់អំណោយសប្បុរសធម៌ដល់អាជ្ញាធរ និង ប្រជាពលរដ្ឋនៅសង្កាត់ស្ទឹងមានជ័យ៣ ”

# ភាពជោគជ័យរបស់អតិថិជន





**អ្នកស្រី អ៊ី ចិត្តត្រា** ( អាជីវករ និង ម្ចាស់កសិដ្ឋានចិញ្ចឹមទា )

*អ្នកស្រី អ៊ី ចិត្តត្រា មានប្រសាសន៍ថា " ការប្រើប្រាស់សេវាកម្ចីរបស់ជោគជ័យ គឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវរបស់ខ្ញុំកន្លងមក។ សេវាកម្មមានភាពរហ័សលើសពីការរំពឹងទុក បើនិយាយពីបុគ្គលិកវិញលោកគ្រូគាត់និយាយស្តីប្រកបដោយក្រមសីលធម៌ ហើយកំឡុងពេលមានវិបត្តិកូវីដនេះគាត់តែងតែមកសួរនាំជួយប្រឹក្សាផ្នែកហិរញ្ញវត្ថុដល់ខ្ញុំធ្វើឲ្យខ្ញុំកាន់តែមានភាពកក់ក្តៅ ចំពោះការប្រើប្រាស់សេវាកម្មពីជោគជ័យ " ។*

ក្នុងទឹកមុខស្រស់ញញឹមរបស់អ្នកស្រី អ៊ី ចិត្តត្រា ក្នុងវ័យ ២៩ឆ្នាំ បានរៀបរាប់ពី ភាពជោគជ័យនៅក្នុងដំណើរអាជីវកម្មរបស់ខ្លួនបន្ទាប់ពីទទួលបានកម្ចីពីជោគជ័យ។ជាមួយជីវិតអាពាហ៍ពិពាហ៍ និងមានកូនប្រុសស្រី ០២នាក់ អ្នកស្រីនិងស្វាមី សព្វថ្ងៃរស់នៅ ភូមិបឹងជ្រោយ ឃុំសូទិន ស្រុកបឹងជ្រោយ ខេត្តកំពង់ចាម។

ដំបូងឡើយ អ្នកស្រី អ៊ី ចិត្តត្រា ជាអ្នកលក់បន្លែត្រីសាច់សាមញ្ញម្នាក់នៅផ្ទះរបស់ខ្លួនដែលមានទីតាំងក្នុងខេត្តកំពង់ចាម ខណៈស្វាមីរបស់គាត់ជាអ្នកនេសាទត្រីទីនោះផងដែរ។ ដោយភាពឆ្លាត រហ័សរហួន ក្នុងការប្រកបរបរអាជីវកម្ម អ្នកស្រី អ៊ី ចិត្រា ក៏បានសម្រេចចិត្តខ្ចីប្រាក់ពីជោគជ័យ ក្នុងទំហំទឹកប្រាក់ ១៦,000,000 រៀល ដើម្បីពង្រីកអាជីវកម្មចាប់ហួយ និងចិញ្ចឹមទាយកពង។

ជាមួយនឹងកិច្ចខិតខំព្យាយាមរបស់អ្នកស្រីធ្វើឲ្យអាជីវកម្មចិញ្ចឹមទាយកពងរបស់គាត់មានការរីកចម្រើនរហូតដល់មានទាចំនួន ១៣00ក្បាល ដែលបច្ចុប្បន្នប្រមូលផលបានជាមធ្យម ៩00គ្រាប់ក្នុងមួយថ្ងៃ។

សម្រាប់គោលដៅក្នុងពេលអនាគត អ្នកស្រីមានគម្រោងស្នើសុំប្រាក់កម្ចីបន្ថែមក្នុងការវិនិយោគទៅលើគ្រឿងឧបករណ៍អគ្គីសនី និងជាឈ្មួញជួញដូរអង្ករបន្ថែមផងដែរ។





## លោកពូ ម៉ី ឈឿន ( កសិករ )

*" បើនិយាយទៅហាក់ដូចជាមិនបានគ្រោងទុក ប៉ុន្តែពេលជួបជាមួយលោកគ្រូខាង ជោគជ័យ ហើយក៏មានគំនិតថាចង់ទិញដីបន្ថែមធ្វើស្រែចំការ ពេលនោះខ្ញុំក៏សម្រេចចិត្តស្នើសុំកម្ចី។ ដូចក្តីប្រាថ្នាមែន បន្ទាប់ពីពង្រីកដីស្រែដាំដុះ ចំនូលរបស់ខ្ញុំក៏ចេះតែកើនឡើង " មានប្រសាសន៏ដោយលោកពូ ម៉ី ឈឿន។*

លំនៅដ្ឋានដ៏ត្រឈឹមត្រឈៃនៅលើទឹកដី ភូមិផ្តៅជុំលិច ស្រុកជើងព្រៃ ខេត្តកំពង់ចាមរបស់លោកពូ ម៉ី ឈឿន អាយុ៤៩ ឆ្នាំ ដែលមានភរិយា និងកូនប្រុសស្រីចំនួន០៦នាក់។ ចាប់តាំងពីការចាប់ដៃគ្នាដំបូងជាគ្រួសាររបស់លោកពូនិងភរិយា ពួកគាត់ប្រកបរបរចិញ្ចឹមជីវិតដោយការដាំដុះស្រូវប្រាំង និង វស្សានៅលើដីទំហំ ០២ហិចតា។

មុនពេលដែលលោកពូសម្រេចចិត្តប្រើប្រាស់សេវាកម្ចី គ្រួសារលោកពូជាមធ្យមទទួលបានចំណូលប្រហែល ១៥លានរៀលក្នុង ១ឆ្នាំពីការធ្វើស្រែប្រាំងនិងវស្សា ដែលបន្ទាប់ពីទូទាត់ចំណាយរួចអាចទទួលបានប្រាក់ចំណេញប្រហែលជាពាក់កណ្តាលនៃចំនូលសរុប។

ដោយឃើញថាចំនាយគ្រួសារមានការកើនឡើងប្តីប្រពន្ធគាត់បានរិះរកមធ្យោបាយក្នុងការបង្កើនប្រភពចំណូល ហើយស្របពេលនោះទទួលដំណឹងថាមានគេលក់ដី ០១ហិចតា ហើយចំពេលលោកគ្រូខាង ជោគជ័យ បានចុះណែនាំគាត់អំពីផលិតផលប្រាក់កម្ចី រួមមកគាត់ក៏សម្រេចចិត្តខ្ចីប្រាក់ពីជោគជ័យចំនួន ៣,០០០ដុល្លារអាមេរិក សម្រាប់រយៈពេល ០៣ឆ្នាំ ក្នុងការទិញដីនោះ។

ក្រោយពេលទទួលបាន ប្រាក់កម្ចីក្នុងការពង្រីកដីស្រែដាំដុះរបស់គាត់រហូតដល់០៣ហិចតា ឃើញថាចំណូលគ្រួសាររបស់គាត់មានការក៏កើនឡើងទ្វេរដង ដែលធ្វើឲ្យជីវភាពគ្រួសារល្អប្រសើរ និងអាចបន្តផ្គត់ផ្គង់តទៀតទោះបីចំណាយមានការកើនឡើងយ៉ាងណាក៏ដោយ។

សម្រាប់ផែនការអនាគត លោកពូនិងភរិយាមានគម្រោងក្នុងការពង្រើករបរអាជីវកម្មបន្ថែមទៀត ជាមួយនឹងការ ចិញ្ចឹមគោក្របីហើយអ្វីដែលគួរបញ្ជាក់ផងដែរថា លោកពូនិងគ្រួសារ និងបន្តណែនាំសេវាកម្ចីនេះដល់បងប្អូនជាពិសេសកូនរបស់គាត់ផ្ទាល់ក្នុងការកសាងគេហដ្ឋានថ្មីខាងមុខនេះ។



# របាយការណ៍ហិរញ្ញវត្ថុ



# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់ជូននូវរបាយការណ៍នេះភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ("ក្រុមហ៊ុន") នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និង សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

## ក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ("ក្រុមហ៊ុន") ក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិតដែលបានបង្កើតនៅព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ ០០០០២៩៥២ ចុះនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីដំណើរការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦។

ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅផ្ទះលេខ ៩-១១ ផ្លូវ វេងស្រេង សង្កាត់ស្ទឹងមានជ័យ ខណ្ឌស្ទឹងមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺផ្តល់ជូននូវសេវាហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពដល់សហគ្រិនខ្នាតតូច និង មធ្យម និងគ្រួសារដែលមានប្រាក់ចំណូលទាបនៅក្នុងប្រទេសកម្ពុជា។

## លទ្ធផលនៃប្រតិបត្តិការ

លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនប្រចាំឆ្នាំ និងស្ថានភាពនៃប្រតិបត្តិការរបស់ក្រុមហ៊ុននាកាលបរិច្ឆេទ ត្រូវបាន កំណត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុចាប់ពីទំព័រទី៨ ដល់ទំព័រទី ៤៧។

ក្រុមប្រឹក្សាភិបាលពុំបានធ្វើការស្នើលើការបែងចែក ឬការប្រកាសភាគលាភ នាចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ នោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះ មានដូចតទៅ៖

| ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទតែងតាំង |
|---|---|---|
| លោក Moon Kyu Choi | ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ |
| លោក Cheon Gil Park | អភិបាល | ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ |
| លោក Jung Hoon Kim | អភិបាលឯករាជ្យ | ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ |



## សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ក្នុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ ត្រូវបានធ្វើសវនកម្មដោយ ក្រុមហ៊ុន ហ្គេន សនថុន (ខេមបូឌា) លីមីតធីត។

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

អនុលោមទៅតាមលក្ខន្តិកៈ របស់ញាតិសម្ព័ន្ធនៃក្រុមហ៊ុនក្រុមប្រឹក្សាភិបាលពុំមានភាគកម្ម ក្នុងភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។

## ព្រឹត្តិការណ៍ក្រោយរបាយការណ៍

មិនមានព្រឹត្តិការណ៍សំខាន់ៗ គួរអោយកត់សម្គាល់ក្នុងកំឡុងពេលចាប់ពីកាលបរិច្ឆេទនៃរបាយការណ៍រហូតដល់កាល បរិច្ឆេទនៃការអនុម័តនៃរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដើម្បីបង្ហាញទិដ្ឋភាពពិតនិងត្រឹមត្រូវ សម្រាប់ស្ថានភាពហិរញ្ញវត្ថុនាកាលបរិច្ឆេទ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទនេះ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

(ក) ជ្រើសរើសគោលនយោបាយគណនេយ្យឱ្យបាន សមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និង ប្រុងប្រយ័ត្ន ហើយបន្ទាប់មក ធ្វើការអនុវត្តគោលនយោបាយទាំងនេះឲ្យមានសង្គតិភាព

(ខ) អនុលោមតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពខ្នាតតូច និងមធ្យម ហើយប្រសិនបើមានការប្រាសចាកណាមួយ ពីស្តង់ដារទាំងនេះក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនេះ ត្រូវបានលាតត្រដាងពន្យល់ និងកំណត់បរិមាណ ឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) ធានាឱ្យបាននូវភាពគ្រប់គ្រាន់ នៃការកត់ត្រាគណនេយ្យ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធិភាព

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានករណីមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវ-កម្មនាពេលអនាគតដែលអាចរំពឹងទុកបាននឹង

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុន ឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចចិត្តសំខាន់ៗ ដែលប៉ះពាល់ដល់ប្រតិបត្តិការនិងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏មានទំនួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ហើយក៏ត្រូវចាត់វិធានការឱ្យសមស្រប ដើម្បីទប់ស្កាត់និងរកឱ្យឃើញការក្លែងបន្លំនិងភាពមិនប្រក្រតី

ផ្សេងៗ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថាក្រុមហ៊ុនបានអនុវត្តតាមរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

### សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយកាណ៍ ចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធនរបាយកាណ៍លំហូរសាច់ប្រាក់ព្រមទាំងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងយ៉ាងសមរម្យ និងបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវទៅតាមស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាការិយបរិច្ឆេទគិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលប្រតិបត្តិការ និងលំហូរសាច់ប្រាក់ របស់ក្រុមហ៊ុនសម្រាប់ក្នុងការិយបរិច្ឆេទ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពខ្នាតតូចនិងមធ្យម និងសេចក្តីណែនាំដែលចេញដោយធនាគារជាតិ នៃកម្ពុជា។

ជំនួស ឱ្យក្រុមប្រឹក្សាភិបាល




**លោក Cheon Gil Park**
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០២១



# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះភាគហ៊ុននិករបស់
## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី

### មតិយោបល់

យើងបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ("ក្រុមហ៊ុន) ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ របាយការណ៍ចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន របាយកាណ៍លំហូរសាច់ ប្រាក់នាក្នុងការិយបរិច្ឆេទ កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ និងសេចក្តីសង្ខេបកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុផ្សេងៗ រួមទាំងគោលនយោបាយគណនេយ្យសង្ខេបសំខាន់ៗ និង ការពន្យល់ទៅលើព័ត៌មានផ្សេងៗ។

តាមមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី នាការិយបរិច្ឆេទ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និង ស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទនេះ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពខ្នាតតូច និងមធ្យម និង សេចក្តីណែនាំដែលចេញដោយធនាគារជាតិនៃកម្ពុជា។

### មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាម ស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងផ្នែកការទទួលខុសត្រូវរបស់ សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ។ យើងមានឯករាជ្យភាព ក្នុងការធ្វើសវនកម្មដោយ អនុលោមតាមស្តង់ដារនៃវិជ្ជាជីវៈគណនេយ្យអន្តរជាតិស្តីពី " ក្រមសីលធម៌ របស់គណនេយ្យករជំនាញ " (រួមជាមួយនឹងស្តង់ដារឯករាជ្យភាពអន្តរជាតិ ដែលហៅកាត់ថា " IESBA Code" ព្រមទាំងតម្រូវការក្រមសីលធម៌ដទៃទៀត ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងបានបំពេញការទទួលខុសត្រូវទៅតាមក្រមសីលធម៌ផ្សេងៗទៀតស្របតាមតម្រូវការទាំងនោះ និងតាម IESBA Code។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មទាំងឡាយដែលយើងទទួលបានគឺគ្រប់គ្រាន់ និងសមរម្យដើម្បីផ្តល់ជូនជាមូលដ្ឋាន សម្រាប់ការបញ្ចេញមតិរបស់យើងខ្ញុំ។

### ព័ត៌មានផ្សេងទៀត

គណៈគ្រប់គ្រង មានទទួលខុសត្រូវចំពោះព័ត៌មានផ្សេងទៀត។ ព័ត៌មានផ្សេងទៀតរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរាប់បញ្ចូលរបាយការណ៍ របស់សវនករនិងរបាយការណ៍ហិរញ្ញវត្ថុដែលយើងទទួលបានមុនកាលបរិច្ឆេទ នៃរបាយការណ៍

របស់សវនករួមទាំងរបាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងថានឹងផ្តល់ជូនយើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនេះ។

មតិយោបល់របស់យើងលើរបាយការណ៍ហិរញ្ញវត្ថុមិនគ្របដណ្តប់លើព័ត៌មានផ្សេងទៀតទេ ហើយយើងមិនបង្ហាញពីទម្រង់ណាមួយនៃការធានាសវនកម្ម ឬការសន្និដ្ឋានណាមួយទៅលើព័ត៌មានទាំងនោះឡើយ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់យើងខ្ញុំគឺអានព័ត៌មានផ្សេងទៀត ដូចដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានទាំងនោះអាចនឹងមានភាពមិនស៊ីសង្វាក់គ្នាជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬចំណេះដឹងរបស់យើងដែលទទួលបានពីការធ្វើសវនកម្មកន្លងមក ឬអាចបង្ហាញពីកំហុសឆ្គងជាសារវន្ត។

ប្រសិនបើផ្អែកលើការអានព័ត៌មានផ្សេងទៀត ដែលយើងទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ ហើយយើងខ្ញុំសន្និដ្ឋានថាមានភាពមិនត្រឹមត្រូវ គួរឱ្យកត់សម្គាល់ណាមួយ យើងខ្ញុំនឹងធ្វើការរាយការណ៍ អំពីភាពមិនប្រក្រតីទាំងនោះតាមភាពជាក់ស្តែង។បន្ទាប់ពីបានអានព័ត៌មានផ្សេងទៀតដែលផ្តល់ជូនដោយគណៈគ្រប់គ្រងនៃក្រុមហ៊ុន យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍អំពីភាពមិនប្រក្រតីនោះទេ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានការរាយការណ៍ខុសជាសារវន្ត យើងខ្ញុំតម្រូវឱ្យរាយការណ៍អំពីបញ្ហាទាំងនោះ ទៅក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ព្រមទាំងឆ្លើយតបនឹងបញ្ហានោះដោយអនុលោមតាមតម្រូវការស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាលេខ ៧២០ (កែសំរួលថ្មី) ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ឱ្យបានត្រឹមត្រូវដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពខ្នាតតូច និងមធ្យម និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមក ពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវចំពោះការវាយតម្លៃសមត្ថភាពក្រុមហ៊ុន ក្នុងការបន្តប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននិរន្តភាព ការលាតត្រដាងប្រសិនជាមានបញ្ហា ទាក់ទងនឹងនិរន្តភាព និងការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តភាព លុះត្រាតែក្រុមប្រឹក្សាភិបាលមានគោលបំណងរំសាយក្រុមហ៊ុនឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេងប៉ុន្តែចាំបាច់ត្រូវធ្វើ។

## ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំគឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយបង្ហាញពីទិដ្ឋិភាពពិត និងពុំមានលក្ខណៈខុសឆ្គងជាសារវន្ត បណ្តាលមក ពីការក្លែងបន្លំ ឬកំហុសឆ្គងនានាក្នុងការធ្វើជាមូលដ្ឋាន លើការបញ្ចេញមតិយោបល់លើរបាយការណ៍សវនកម្ម របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផលគឺជាការធានាមួយដែលមានកម្រិតខ្ពស់ ប៉ុន្តែវាមិនបាន ធានាថាការធ្វើសវនកម្ម ដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលមានឡើយ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាមានលក្ខណៈជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ច របស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យនិងការរក្សាមជ្ឈធាតុនិយម ប្រកបទៅដោយវិជ្ជាជីវៈក្នុងអំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់ និងវាយតម្លៃនូវហានិភ័យទាក់ទងនឹងការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុថា តើវាកើតឡើងដោយការក្លែងបន្លំឬដោយកំហុសឆ្គង រៀបចំនិងអនុវត្តនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្ម ឱ្យបានគ្រប់គ្រាន់ និងសមស្រប ដើម្បីគាំទ្រជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែល មិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងដោយអចេតនា ដោយសារតែការក្លែងបន្លំរួមបញ្ចូល ទាំងការឃុបឃិតការក្លែងបន្លំឯកសារការលុបចោលដោយចេតនាការបង្ហាញខុស ឬ ការល្មើសទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុង ដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់ លើប្រសិទ្ធិភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។
- ធ្វើការវាយតម្លៃភាពសមស្របលើ គោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ព្រមទាំងលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។
- ធ្វើការសន្និដ្ឋានដ៏សមស្របទៅលើការប្រើប្រាស់មូលដ្ឋាននិរន្តភាពគណនេយ្យរបស់ក្រុមប្រឹក្សាភិបាល ដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានថា តើភាពមិនប្រាកដប្រជាជាសារវន្ត ដែលអាចកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍នានា ឬលក្ខខណ្ឌផ្សេងទៀតដែលបណ្តាលឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពបន្តនិរន្តភាពរបស់ក្រុមហ៊ុនឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាភាពមិនប្រាកដ

ប្រជា ជាសារវន្តណាមួយអាចនឹងកើតមានឡើងយើងខ្ញុំតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ទាំងនោះ ក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍របស់ក្រុមប្រឹក្សាភិបាល ទៅលើភាពមិនប្រក្រតីទាំងនោះ ឬក៏ប្រសិនបើការលាតត្រដាងនោះនៅមិនគ្រប់គ្រាន់យើងខ្ញុំនឹងធ្វើការបញ្ចេញមតិយោបល់ថារបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនបានបង្ហាញទិដ្ឋិភាពពិត និងត្រឹមត្រូវ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន គិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាព ឬព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តភាពបាន។

- វាយតម្លៃការបង្ហាញទូទៅរចនាសម្ព័ន្ធ និង ខ្លឹមសាររបស់របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងនានា ថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការនិងព្រឹត្តិការណ៍នានា ដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាល ទៅលើបញ្ហាផ្សេងៗ ទំហំការងារនិងពេលវេលាក្នុងការធ្វើសវនកម្មព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងកង្វះខាតធំៗមួយចំនួននៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញអំឡុងពេលធ្វើសវនកម្ម។

យើងខ្ញុំក៏ផ្តល់ជូន ក្រុមប្រឹក្សាភិបាលនូវសេចក្តីថ្លែងការណ៍មួយដែលយើងខ្ញុំបានអនុវត្តទៅតាមតម្រូវការ ក្រមសីលធម៌ដែលទាក់ទងនឹងឯករាជ្យភាព ហើយយើងខ្ញុំធ្វើការរាយការណ៍ជូនក្រុមប្រឹក្សាភិបាលនូវបញ្ហាទាំងអស់ ដែលនឹងគិតថាសមហេតុផលទៅលើឯករាជ្យភាពរបស់យើងខ្ញុំ និងការការពារដែលអាចមាន។

Grant Thornton

**ហ្រ្គេន សនថុន ខេមបូឌា លីមីតធីត**
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

**Ronald C. Almera**
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | ៥៥,៦១៦ | ២២៤,៩៦៧ | ៥៥,២៣៨ | ២២៥,០៩៥ |
| ប្រាក់បញ្ញើនិងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | ១៧៨,០៤៧ | ៧២០,២០០ | ១៧៧,១៧១ | ៧២១,៩៧២ |
| ប្រាក់បញ្ញើ និងតម្កល់នៅធនាគារនានា | ១,៣៦០,២២៩ | ៥,៥០២,១២៦ | ២ ,០៣៧,៣៩៨ | ៨,៣០២,៣៩៧ |
| ឥណទានទៅអោយអតិថិជន | ៣១,២២៦,៤៩០ | ១២៦,៣១១,១៥២ | ២១,៥៣៧,៤៩១ | ៨៧,៧៦៥,២៧៦ |
| ទ្រព្យសកម្មផ្សេងៗ | ១២៨,៩៧១ | ៥២១,៦៨៨ | ៥៦,៧៦៥ | ២៣១,៣១៧ |
| ទ្រព្យ និង បរិក្ខារ | ៤១៦,១៥៤ | ១,៦៨៣,៣៤៣ | ៣៦០,៦៩០ | ១,៤៦៩,៨១២ |
| ទ្រព្យអរូបី | ២៤៣,៨៦១ | ៩៨៦,៤១៨ | ១០២,៥៧៨ | ៤១៨,០០៥ |
| **ទ្រព្យសកម្មសរុប** | **៣៣,៦០៩,៣៦៨** | **១៣៥,៩៤៩,៨៩៤** | **២៤,៣២៧,៣៣១** | **៩៩,១៣៣,៨៧៤** |

| | | | | |
|---|---|---|---|---|
| **មូលធន** | | | | |
| ភាគហ៊ុនដើមទុន | ៣,៥០០,០០០ | ១៤,០៦៣,០០០ | ៣,៥០០,០០០ | ១៤,០៦៣,០០០ |
| ប្រាក់ចំណេញរក្សាទុក/ ខាតបង្គរ | ៣០៣,១០១ | ១,២៤៧,៨៥៨ | (២២២,៧៧៩) | (៨៩៦,១៥៥) |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ២៤៩,៧៣៤ | ១,០០៧,៣៩៥ | ៣៨៨,៥៧៤ | ១,៥៧៣,៤៤៦ |
| លម្អៀងនៃការប្តូររូបិយប័ណ្ណ | - | ៧៥,៤៦៥ | - | ១៩៧,៨២៥ |
| **មូលធនសរុប** | **៤,០៥២,៨៣៥** | **១៦,៣៩៣,៧១៨** | **៣,៦៦៥,៧៩៥** | **១៤,៩៣៨,១១៦** |
| **បំណុល** | | | | |
| គណនីពាណិជ្ជ និងគណនីត្រូវទូទាត់ផ្សេងៗ | ២៨៣,៩២៦ | ១,១៤៨,៤៨១ | ៣៨៧,៤៥៩ | ១,៥៧៨,៨៩៥ |
| កម្ចីរយៈពេលខ្លី | ១៣,៧៤២,០៩៥ | ៥៥,៥៨៦,៧៧៤ | ៦,៧៤២,៣៨០ | ២៧,៤៧៥,១៩៧ |
| កម្ចីរយៈពេលវែង | ១៥,៥០០,០០០ | ៦២,៦៩៧,៥០០ | ១៣,៥០០,០០០ | ៥៥,០១២,៥០០ |
| ពន្ធលើប្រាក់ចំណូលត្រូវបង់ | ៣០,៥១២ | ១២៣,៤២១ | ៣១,៦៩៧ | ១២៩,១៦៥ |
| **បំណុលសរុប** | **២៩,៥៥៦,៥៣៣** | **១១៩,៥៥៦,១៧៦** | **២០,៦៦១,៥៣៦** | **៨៤,១៩៥,៧៥៧** |
| **បំណុល និងមូលធនសរុប** | **៣៣,៦០៩,៣៦៨** | **១៣៥,៩៤៩,៨៩៤** | **២៤,៣២៧,៣៣១** | **៩៩,១៣៣,៨៧៤** |



# របាយការណ៍ ចំណូលពេញលេញ

| | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ៤,២៥៩,៤៨០ | ១៧,៣៦៥,៩០០ | ៣,៤៣៩,៩៧៩ | ១៣,៩៣៨,៧៩៤ |
| ចំណាយការប្រាក់ | (១,២៨២,៣៩០) | (៥,២២៨,៣០៤) | (៩៥២,៤៨៦) | (៣,៨៥៩,៤៧៣) |
| **ចំណូលការប្រាក់សុទ្ធ** | **២,៩៧៧,០៩០** | **១២,១៣៧,៥៩៦** | **២,៤៨៧,៤៩៣** | **១០,០៧៩,៣២១** |
| ប្រាក់ចំណូលផ្សេងៗ | ៦៦,៨៩១ | ២៧២,៧១៥ | ៥៥,៨៧៨ | ២២៦,៤១៨ |
| ចំណាយទូទៅ និងរដ្ឋបាល | (២,៤៧៣,៧៦៤) | (១០,០៨៥,៥៣៦) | (១,៨៦៩,៩៣៩) | (៧,៥៧៦,៩៩៣) |
| សំវិធានធនសម្រាប់ឥណទានបាត់បង់និងជាប់សង្ស័យ | (៦៩,៥០៥) | (២៨៣,៣៧២) | ២៣,៤៣៨ | ៩៤,៩៧១ |
| **ប្រាក់ចំណូលមុនបង់ពន្ធ** | **៥០០,៧១២** | **២,០៤១,៤០៣** | **៦៩៦,៨៧០** | **២,៨២៣,៧១៧** |
| ចំណាយពន្ធលើប្រាក់ចំណូល | (១១៣,៦៧២) | (៤៦៣,៤៤១) | (៦៧,២៩៦) | (២៧២,៦៨៣) |
| **ប្រាក់ចំណូលសុទ្ធក្នុងការិយបរិច្ឆេទ** | **៣៨៧,០៤០** | **១,៥៧៧,៩៦២** | **៦២៩,៥៧៤** | **២,៥៥១,០៣៤** |
| ចំណូលពេញលេញផ្សេងៗ លម្អៀងពីអត្រាប្តូររូបិយប័ណ្ណ | - | (១២២,៣៦០) | - | ១៨៧,៥៤៧ |
| **សរុបចំណូលពេញលេញសម្រាប់ការិយបរិច្ឆេទ** | **៣៨៧,០៤០** | **១,៤៥៥,៦០២** | **៦២៩,៥៧៤** | **២,៧៣៨,៥៨១** |

# របាយការណ៍បម្រែបម្រួលមូលធន

| | ដើមទុន | | ទុនបម្រុង | | ចំណេញរក្សាទុក | | ទុនបម្រុងតាមបទបញ្ញត្តិ | | លម្អៀងនៃការប្តូររូបិយប័ណ្ណ | ដើមទុនសរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ៣,៥០០,០០០ | ១៤,០៦៣,០០០ | - | - | (២២២,៧៧៩) | (៨៩៦,១៥៥) | ៣៨៨,៥៧៤ | ១,៥៧៣,៤៤៦ | ១៩៧,៨២៥ | ៣,៦៦៥,៧៩៥ | ១៤,៩៣៨,១១៦ |
| ចំណេញក្នុងគ្រា | - | - | - | - | ៣៨៧,០៤០ | ១,៥៧៧,៩៦២ | - | - | - | ៣៨៧,០៤០ | ១,៥៧៧,៩៦២ |
| ផ្ទេរទៅទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | ១៣៨,៨៤០ | ៥៦៦,០៥១ | (១៣៨,៨៤០) | (៥៦៦,០៥១) | - | - | - |
| លម្អៀងនៃការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | (១២២,៣៦០) | - | (១២២,៣៦០) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០** | **៣,៥០០,០០០** | **១៤,០៦៣,០០០** | **-** | **-** | **៣០៣,១០១** | **១,២៤៧,៨៥៨** | **២៤៩,៧៣៤** | **១,០០៧,៣៩៥** | **៧៥,៤៦៥** | **៤,០៥២,៨៣៥** | **១៦,៣៩៣,៧១៨** |

| | ដើមទុន | | ទុនបម្រុង | | ខាតបង្គរ | | ទុនបម្រុងតាមបទបញ្ញត្តិ | | លម្អៀងនៃការប្តូររូបិយប័ណ្ណ | ដើមទុនសរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ | ១,៥០០,០០០ | ៦,០២៧,០០០ | ២,០០០,០០០ | ៨,០៣៦,០០០ | (៦១៤,៦២០) | (២,៤៨៣,៨៩៥) | ១៥០,៨៤១ | ៦១០,១៥២ | ១០,២៧៨ | ៣,០៣៦,២២១ | ១២,១៩៩,៥៣៥ |
| ទុនចូលរួមបន្ថែមក្នុងគ្រា | ២,០០០,០០០ | ៨,០៣៦,០០០ | (២,០០០,០០០) | (៨,០៣៦,០០០) | - | - | - | - | - | - | - |
| ចំណេញក្នុងគ្រា | - | - | - | - | ៦២៩,៥៧៤ | ២,៥៥១,០៣៤ | - | - | - | ៦២៩,៥៧៤ | ២,៥៥១,០៣៤ |
| ផ្ទេរពីខាតបង្គរទៅទុនបម្រុងតាមបទបញ្ញត្តិ | - | - | - | - | (២៣៧,៧៣៣) | (៩៦៣,២៩៤) | ២៣៧,៧៣៣ | ៩៦៣,២៩៤ | - | - | - |
| លម្អៀងនៃការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ១៨៧,៥៤៧ | - | ១៨៧,៥៤៧ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | **៣,៥០០,០០០** | **១៤,០៦៣,០០០** | **-** | **-** | **(២២២,៧៧៩)** | **(៨៩៦,១៥៥)** | **៣៨៨,៥៧៤** | **១,៥៧៣,៤៤៦** | **១៩៧,៨២៥** | **៣,៦៦៥,៧៩៥** | **១៤,៩៣៨,១១៦** |

# របាយការណ៍លំហូរសាច់ប្រាក់

| | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញមុនបង់ពន្ធ | ៥០០,៧១២ | ២,០៤១,៤០៣ | ៦៩៦,៨៧០ | ២,៨២៣,៧១៧ |
| និយ័តកម្មសម្រាប់៖ | | | | |
| រំលស់ទ្រព្យរូបី | ១៤៣,៧០៧ | ៥៨៥,៨៩៣ | ៧២,៥៤១ | ២៩៣,៩៣៦ |
| រំលស់ទ្រព្យអរូបី | ១៥,៧៩៧ | ៦៤,៤០៤ | ៣,៤៥៩ | ១៤,០១៦ |
| សំវិធានធនសម្រាប់ឥណទានបាត់បង់ និងជាប់សង្ស័យ | ៦៩,៥០៥ | ២៨៣,៣៧២ | (២៣,៤៣៨) | (៩៤,៩៧១) |
| **ប្រតិបត្តិការចំណេញមុនបម្រែបម្រួលទុនបង្វិល** | ៧២៩,៧២១ | ២,៩៧៥,០៧២ | ៧៤៩,៤៣២ | ៣,០៣៦,៦៩៨ |
| **បម្រែបម្រួលនេះ** | | | | |
| ប្រាក់តម្កល់ធានាលើដើមទុន | - | - | (១០០,០០០) | (៤០៥,២០០) |
| ប្រាក់បញ្ញើមានកំណត់ | ១,៤០០,០០០ | ៥,៧០៧,៨០០ | (១,៤០០,០០០) | (៥,៦៧២,៨០០) |
| ឥណទានទៅអតិថិជន | (៩,៧៥៨,៥០៤) | (៣៩,៧៨៥,៤២១) | (៨,២៤៣,៧៦២) | (៣៣,៤០៣,៧២៣) |
| ទ្រព្យផ្សេងៗ | (៦៧,០៤០) | (២៧៣,៣២២) | (៤០,៥១៧) | (១៦៤,១៧៥) |
| បំណុលផ្សេងៗ | (១១៧,៣០៩) | (៤៧៨,២៦៩) | ១១៤,៦៧៨ | ៤៦៤,៦៧៥ |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពប្រតិបត្តិការ** | (៧,៨១៣,១៣២) | (៣១,៨៥៤,១៤០) | (៨,៩២០,១៦៩) | (៣៦,១៤៤,៥២៥) |
| ពន្ធលើប្រាក់ចំណូលដែលបានបង់រួច | (១១៤,៨៥៧) | (៤៦៨,២៧២) | (៣៥,៥៩៩) | (១៤៤,២៤៧) |
| **សាច់ប្រាក់សុទ្ធប្រើនៅក្នុងសកម្មភាពប្រតិបត្តិ** | **(៧,៩២៧,៩៨៩)** | **(៣២,៣២២,៤១២)** | **(៨,៩៥៥,៧៦៨)** | **(៣៦,២៨៨,៧៧២)** |
| **សកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យសកម្ម | (១៩៩,១៧១) | (៨១២,០២០) | (២៥២,៦៧៤) | (១,០២៣,៨៣៥) |
| ការទិញទ្រព្យអរូបី | (១៥៧,០៨០) | (៦៤០,៤១៥) | (៧៩,០៣៥) | (៣២០,២៥០) |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | **(៣៥៦,២៥១)** | **(១,៤៥២,៤៣៥)** | **(៣៣១,៧០៩)** | **(១,៣៤៤,០៨៥)** |
| **សកម្មភាពហិរញ្ញប្បទាន** | | | | |
| កម្ចីក្នុងគ្រា | ១២,២៥៨,៣២៥ | ៤៩,៩៧៧,១៩១ | ៨,២៤៧,៥៤៦ | ៣៣,៤១៩,០៥៦ |
| ការទូទាត់សងប្រាក់កម្ចី | (៣,២៥០,០០០) | (១៣,២៥០,២៥០) | (១,០០០,០០០) | (៤,០៥២,០០០) |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មហិរញ្ញប្បទាន** | **៩,០០៨,៣២៥** | **៣៦,៧២៦,៩៤១** | **៧,២៤៧,៥៤៦** | **២៩,៣៦៧,០៥៦** |
| **បម្រែបម្រួលសាច់ប្រាក់សុទ្ធក្នុងដៃនិងសាច់ប្រាក់សមមូល** | ៧២៤,០៨៥ | ២,៩៥២,០៩៤ | (២,០៣៩,៩៣១) | (៨,២៦៥,៨០១) |
| សាច់ប្រាក់ក្នុងដៃនិងសាច់ប្រាក់សមមូលដើមគ្រា | ៦៩៤,៨០៧ | ២,៨៣១,៣៣៩ | ២,៧៣៤,៧៣៨ | ១០,៩៨៨,១៧៧ |
| លម្អៀងនៃការប្តូររូបិយប័ណ្ណ | - | (៤៤,០១៥) | - | ១០៨,៩៦៣ |
| **សាច់ប្រាក់ក្នុងដៃនិងសាច់ប្រាក់សមមូលចុងគ្រា** | **១,៤១៨,៨៩២** | **៥,៧៣៩,៤១៨** | **៦៩៤,៨០៧** | **២,៨៣១,៣៣៩** |

## ការិយាល័យកណ្តាល


វេបសាយ៖ www.chokchey.com.kh
អ៊ីម៉ែល៖ info@chokchey.com.kh
លេខទូរស័ព្ទ៖ (855) 23 922 126
អគារលេខ ៩-១១ ផ្លូវវេងស្រេង សង្កាត់ស្ទឹងមានជ័យទី៣
ខណ្ឌមានជ័យ, រាជធានីភ្នំពេញ